# មេរៀនទី ១២៖ ព្រះយេស៊ូវបង្រៀនអំពីរទ្វាន់

## លូកា ៦៖១៧-២៦

**មេរៀន** ( *យូធូបលីង* )៖ https://youtu.be/37192aU9U3k

**រឿងនៅក្នុងព្រះគម្ពីរសម្រាប់កុមារ៖** https://youtu.be/GnWwnOPQM_U

**គោលបំណង៖** ព្រះយេស៊ូវចង់ឲ្យយើងស្វែងរកនគរព្រះជាមុនសិន

**ខគម្ពីរចងចាំ៖ ម៉ាថាយ ៦៖៣៣** *"ចូរស្វែងរកនគរ និងសេចក្ដីសុចរិតនៃព្រះជាមុនសិន ទើបគ្រប់របស់ទាំងនោះ នឹងបានប្រទានមកអ្នករាល់គ្នាថែមទៀតផង"។*

**ចំរៀង** ( *យូធូបលីង* )៖

១. បើទ្រង់គង់ជាមួយ https://youtu.be/2CzIW4_ueg0
២. ខ្ញុំនឹងទុកចិត្តទ្រង់ https://youtu.be/WCZlwlstAzc
៣. ព្រះយេស៊ូវស្រឡាញ់កុមារណាស់ https://youtu.be/8iUI62Zo_Co

### ១. អធិស្ឋាន

### ២. ចំរៀង ( *រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស* )

### ៣. ល្បែងកំសាន្ត « តើអ្នកមើលឃើញអ្វី ? »

សូមបោះពុម្ពរូបភាពដែលនៅទំព័រខាងក្រោមបង្ហាញដល់កុមារ។ អ្នកអាចមើលឃើញរូបភាពទាំងនេះមានរូបពីរផ្សេងគ្នា។ សួរកុមារថាតើពួកគេមើលឃើញអ្វី ?



សត្វទា ឬទន្សាយ ?



ថូផ្កា ឬមុខមនុស្ស២នាក់ ?



ក្មេងស្រី ឬស្ត្រីចំណាស់ ?

ពន្យល់កុមារថាអ្វីដែលយើងមើលឃើញនៅក្នុងពិភពលោកនេះ អាចនឹងមិនមែនជាអ្វីដែលយើងកំពុងតែឃើញវានោះក៏ថាបាន។ អ្វីដែលមនុស្សគិតថាជារឿងសំខាន់អាចនឹងមិនមែនជារឿងសំខាន់ នៅក្នុងព្រះនេត្ររបស់ព្រះ។

### ៤. ការណែនាំមេរៀន

តើអ្នកគិតថាអ្វីនឹងធ្វើឱ្យមនុស្សសប្បាយចិត្ត? (មិត្តភ័ក្តិច្រើន លុយ ផ្ទះស្អាត ប្រដាប់ក្មេងលេង ខោអាវ ទូរស័ព្ទថ្មី) ប៉ុន្តែបើខ្ញុំទិញទូរស័ព្ទថ្មីឱ្យអ្នកថ្ងៃនេះ តើសុភមង្គលអ្នកនឹងនៅបានយូរប៉ុណ្ណា? តើអ្នកនឹងសប្បាយចិត្តជារៀងរហូតទេ? ទេ អ្វីៗក្នុងលោកនេះ មិនអាចធ្វើឲ្យយើងសប្បាយចិត្តជារៀងរហូតនោះទេ។

យើងនឹងសប្បាយចិត្តក្នុងរយៈពេលខ្លី ប៉ុន្តែយើងនឹងចង់បានរបស់ច្រើនទៀត និងរបស់ល្អជាងមុនៗទៅទៀត។ ព្រះមិនចង់ឱ្យយើងរស់នៅដើម្បីតែរបស់របរនៅក្នុងលោកីយ៍នេះប៉ុណ្ណោះទេ។ ទ្រង់ចង់បង្រៀនយើងថា មានអ្វីផ្សេងៗជាច្រើនទៀតដែលសំខាន់ជាងការដែលយើងគ្រាន់តែរស់នៅដើម្បី ចង់បានតែរបស់នៅលោកីយ៍នេះទៅទៀត។ សូមយើងរៀនអំពីអ្វីដែលអ្វីនៅក្នុងរឿងព្រះគម្ពីរថ្ងៃនេះចង់ប្រាប់យើង។

## ៥. រឿងនៅក្នុងព្រះគម្ពីរ

សាច់រឿងនៅក្នុងព្រះគម្ពីរថ្ងៃនេះ ព្រះយេស៊ូវបានមានបន្ទូលអំពីអ្វីៗទាំងអស់មិនមែនតែងតែកើតឡើងដោយសមហេតុផលហេតុនោះទេ ។ ព្រះអង្គមានបន្ទូលថា **លូកា ៦៖២០-២២** “មានពរហើយ អ្នករាល់គ្នាដែលក្រអើយ ដ្បិតនគរព្រះជារបស់ផងអ្នករាល់គ្នា។ មានពរហើយ អ្នករាល់គ្នាដែលឃ្លានឥឡូវនេះ ដ្បិតអ្នករាល់គ្នានឹងបានឆ្អែត មានពរហើយ អ្នករាល់គ្នាដែលយំឥឡូវនេះ ដ្បិតអ្នករាល់គ្នានឹង បានសើចវិញ។ មានពរហើយ កាលណាមនុស្សនឹងស្អប់អ្នករាល់គ្នា ព្រមទាំងកាត់កាល ត្មះតិះដៀល ហើយចោលឈ្មោះអ្នករាល់គ្នាចេញ ទុកដូចជាអាក្រក់ ដោយព្រោះកូនមនុស្ស។”

ព្រះអង្គក៏មានបន្ទូលដែរថា **លូកា ៦៖២៤-២៦** “តែវេទនាដល់អ្នករាល់គ្នាជាអ្នកមាន ដ្បិតអ្នករាល់គ្នាកំពុង
តែមានសេចក្តីកំសាន្តចិត្តក្នុងសម័យនេះ។ វេទនាដល់អ្នករាល់គ្នាដែលឆ្អែត ដ្បិតនឹងត្រូវឃ្លានវិញវេទនាដល់អ្នករាល់គ្នា ដែលសើចក្នុងជាន់ឥឡូវនេះ ដ្បិតនឹងកើតទុក្ខព្រួយ ហើយយំសោកវិញ។ វេទនាដល់អ្នករាល់គ្នា កាលណាមនុស្សទាំងអស់និយាយល្អពីអ្នករាល់គ្នា ពីព្រោះកាលពីដើម ពួកឰយុកោបានប្រព្រឹត្តនឹងពួកហោរាក្លែងក្លាយយ៉ាងដូច្នោះដែរ។”

ព្រះមានបន្ទូលថា មានពរហើយ អ្នករាល់គ្នាដែលក្រអើយ ដ្បិតនគរព្រះជារបស់ផងអ្នករាល់គ្នា។ ទ្រង់ក៏មានបន្ទូលថា តែវេទនាដល់អ្នករាល់គ្នា ជាអ្នកមើលទៅដូចជាមានគ្រប់យ៉ាងដែលពួកគេចង់បាន។ ទ្រង់មានបន្ទូលថាអ្នកដែលមានមិត្តភក្តិច្រើន ហើយអ្នកទាំងនោះអាចនឹងមិនមែនជាមិត្តភក្តិជាមួយនឹងព្រះអង្គទេ។ ទ្រង់មានបន្ទូលថាអស់អ្នកដែលមើលទៅមានអាចនឹងក្រខ្លាំងណាស់ពីព្រោះពួកគេមិនស្គាល់ព្រះទេ។

ព្រះយេស៊ូចង់ឲ្យមនុស្សបានដឹងថា ពួកគេត្រូវប្រុងប្រយ័ត្ននៅពេលដែលពួកគេសម្រេចចិត្តចង់បាននូវរបស់អ្វីមួយសម្រាប់ជីវិតរបស់ពួកគេ។ ប្រសិនបើអ្នកជ្រើសរើសដើរតាមព្រះយេស៊ូវ អ្នកអាចប្រឈមមុខនឹងការបៀតបៀន ទុក្ខលំបាក ការរើសអើង និងការមិនចូលចិត្តពីអ្នកដទៃ ប៉ុន្តែអ្នកត្រូវចាំថា ព្រះតែងតែនៅជាមួយអ្នក។ ព្រះតែងតែឆ្លើយតបនឹងការអធិស្ឋានរបស់អ្នក ពេលយើងទូលសូមដល់ទ្រង់។ ព្រះសន្យាថានឹងប្រទានពរដល់យើង យើងនឹងទទួលបានរង្វាន់ទាំងនៅលើផែនដី និងនៅនគរស្ថានសួគ៌ផងដែរ។

## ៦. សំនួរពិភាក្សា

ក. តើក្នុងព្រះគម្ពីរនិយាយថាយើងគួរតែស្វែងរកអ្វីក្នុងជីវិតយើង? (*នគររបស់ព្រះ*)

ខ. តើប្អូនធ្វើអ្វីដើម្បីឲ្យបានរង្វាន់ពីព្រះ ?(*ដើរតាមផ្លូវរបស់ព្រះ*)

គ.តើអ្នកអាចស្វែងរកនគររបស់ព្រះនៅក្នុងជីវិតរបស់អ្នកដោយរបៀបណា?(*ដោយការជ្រើសរើសផ្លូវរបស់ព្រះក្នុងការរស់នៅ និង អនុវត្តន៍តាមព្រះបន្ទូលរបស់ទ្រង់*)

## ៧. ល្បែងកំសាន្ត «ស្វែងរកកំណប់»

សំភារៈដែលត្រូវការ៖ ស្កុគ្រាប់ និងព្រះគម្ពីរ ៣ក្បាល

ក. លាក់ស្កុគ្រាប់ និងព្រះគម្ពីរនៅក្នុងថ្នាក់រៀន

ខ. ឲ្យកុមារស្វែងរកអ្វីដែលគិតថាជាកំណប់ពិតប្រាកដ

គ. កុមារដែលយកព្រះគម្ពីរមកជាអ្នកឈ្នះ។ សូមឲ្យស្កុគ្រាប់ច្រើនទៅកុមារនោះ។

ឃ. ពន្យល់កុមារថាពេលដែលយើងស្វែងរកនគរព្រះជាមុន (*ផ្លូវរបស់ព្រះ*) យើងនឹងបានព្រះពរច្រើនជាងពេលដែលយើងស្វែងរកផ្លូវរបស់លោកីយ៍។

### ៨. ខគម្ពីរចងចាំ

**ម៉ាថាយ ៦៖៣៣** *"ចូរស្វែងរកនគរ និងសេចក្ដីសុចរិតនៃព្រះជាមុនសិន ទើបគ្រប់របស់ទាំងនោះ នឹងបានប្រទានមកអ្នករាល់គ្នាថែមទៀតផង"*។

### ៩. ហាត្ថកម្ម

ផាត់ពណ៌លើរូបភាព - **ម៉ាថាយ ៦៖៣៣**

### ១០. ចំរៀង (*រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស*)

### ១១. អធិស្ឋាន

**ការថ្វាយបង្គំសំរាប់គ្រូ៖ (សូមអាន ហើយអធិស្ឋានមុនពេលចាប់ផ្ដើមបង្រៀន)**
តើទំនាក់ទំនងរបស់អ្នកជាមួយនឹងព្រះមានឥទ្ធិពលបែបណាដែរដែរ? នៅក្នុងគ្រាលំបាកតើ ទំនាក់-ទំនងរបស់អ្នកជាមួយនឹងព្រះមានលក្ខណៈយ៉ាងណាដែរ? ចូរអរព្រះគុណចំពោះពេលវេលាដ៏ល្អ ប៉ុន្តែក៏ត្រូវដឹងគុណចំពោះគ្រាដ៏លំបាកដែលអាចទាញយើងឲ្យខិតទៅជិតព្រះអម្ចាស់ផងដែរ។ ថ្ងៃនេះ សូមអធិស្ឋានសម្រាប់នរណាម្នាក់ដែលកំពុងតែជួបការលំបាក ថាការលំបាកនោះនឹងជួយគាត់ឱ្យកាន់តែមានទំនាក់ទំនងជិតស្និទ្ធជាមួយព្រះអម្ចាស់បបន្ថែមទៀត។។

រូបភាពទី១- សត្វទា ឬទន្សាយ?



រូបភាពទី២- ផ្កា ឬមុខមនុស្ស២?




រូបភាពទី៣- ក្មេងស្រី ឬស្ត្រីចំណាស់ ?




ម៉ាថាយ ៦៖៣៣
ចូរស្វែងរកនគរ និងសេចក្ដីសុចរិតនៃ
ព្រះជាមុនសិន ទើបគ្រប់របស់ទាំងនោះ
នឹងបានប្រទានមកអ្នករាល់គ្នា
ថែមទៀតផង